# អារម្ភកថា

រឿង « **គេចាប់ស្រីម្នាក់** » គឺជារឿងមួយដែលទាក់ទងនឹងផ្នែកអាថ៌កំបាំងដ៏ជ្រាលជ្រៅបំផុត . ហើយដែលអ្នករងគ្រោះបាននិយាយផ្ទាល់ដោយខ្លួនឯង ។ ជាការពិតណាស់ហើយថា ប្រលោមលោក គឺតែងតែមានលក្ខណៈអស្ចារ្យអណ្ដូង. វង្វេងវង្វល. និងការកំប្លែងខ្លះ ដើម្បីឱ្យមានលក្ខណៈជាប្រលោមលោក ។ សៀវភៅនេះមានលក្ខណៈជា « **ប្រលោមលោកផ្នែកអាថ៌កំបាំង** » ដែលជាដំបូន្មានមួយ ឱ្យនារីទាំងឡាយមានការប្រយ័ត្នខ្លួន ... ពីព្រោះនារីគឺជារង្វង់បាញ់ទី១ ដែលបុរសប្រាថ្នាជាទីបំផុត ...

សូមឧទ្ទិសស្នាដៃនេះ ជូនដល់ព្រលឹងមិត្តយុទ្ធជនដែលបានបាត់បង់ជីវិតនៅក្នុងសមរភូមិ ហើយនិងជូនដល់យុទ្ធជនដែលកំពុងតស៊ូ សំរាប់អានកំសាន្តមួយរយៈកាល ...

ពាក្យថា « **ខ្ញុំ** » គឺជាសំដីនិយាយរបស់នារីរងគ្រោះ ...

**ទង់ ងៀប**

# ១

# វិចិត្រករ

ខ្ញុំបានមើលវិចិត្រករ កំពុងគូររូបលើផ្ទាំងក្រដាសស ដែលដាក់ភ្ជាប់នឹងក្តារខៀនបញ្ឈរ ។ គឺជាយុវវិចិត្រករដ៏មានរូបឆោមផុតលោកិយ. កេសីពណ៌ ខ្មៅរួញអង្កាជី. ស្មាទូលាយ. ចង្កេះឆ្មារ ជាអត្តពលិក ។ វិចិត្រ. នេះជានាមរបស់គេ ។ ខ្ញុំគយគន់យុវបុរសនេះយូរ. ដោយឥតធុញទ្រាន់ទាល់តែសោះ ហើយដួងចិត្តខ្ញុំរំភើបគ្រប់ៗគ្រា...

កាលៈទេសៈនេះ គួរណាស់តែខ្ញុំទុកពេលឱ្យបុរសនេះ ធ្វើការរបស់ខ្លួនក៏ប៉ុន្តែចំណង់នៃការដើរលេងរបស់ខ្ញុំ បានលុកទន្ទ្រានមកក្នុងដួងចិត្តខ្ញុំ ។ ខ្ញុំជានារីក្រមុំពេញក្បាលទឹកដូចទឹកឃ្មុំដូច្នោះ ។ ខ្ញុំជាស្រី

ហើយព្រះអាទិទេពពិតជា យកចុងឫស្សីមកសាងស្ត្រី ព្រោះតែហេតុនេះហើយបានជាខ្ញុំនៅមិននឹងនសោះ ។

– បងវិចិត្រឯងមិនគិតជូនខ្ញុំទៅដើរកំសាន្តទេឬ ? ថ្ងៃនេះជាថ្ងៃអាទិត្យ ... គេបង្កើតថ្ងៃអាទិត្យដើម្បីសម្រាកមិនថាអីចឹង ?

យុវជនបន្តការផាត់គំនូរតទៅទៀត ដោយឥតងាកមើលមុខខ្ញុំឡើយ ។ តិរិយាបថយ៉ាងដូច្នេះ គឺបន្ថែមកំហឹងរបស់ខ្ញុំឱ្យកាន់តែឆេះឆួលឡើង ។ ខ្ញុំប្រើនេត្រាដ៏មុតដូចពស់វែក សម្លក់សម្លឹងយុវបុរសពីក្រោយ. ក៏ប៉ុន្តែឥតប្រយោជន៍សោះ ។ ខ្ញុំដើរទៅជិតក្ដារខៀនបញ្ឈរហើយខ្ញុំយកដៃកាន់ស្មាវិចិត្រករជាទី ស្រឡាញ់នេះ ។

– បងវិចិត្រ គួរតែបងយល់ចិត្តអូនជាស្រីណាស់ ។ មួយអាទិត្យហើយដែលអូនមកកាន់ផ្ទះបង ដើម្បីមើលបងគូរគំនូរដោយសង្ឃឹមថា កាលបើគូរផ្ទាំងគំនូរទី១រួចហើយ បងនឹងនាំអូនដើរកំសាន្ត ... ក៏ប៉ុន្តែអនិច្ចាផ្ទាំងទី២ ផ្ទាំងទី៣ រហូតដល់ទី៧រួចស្រេចបាច់អស់ក៏បងនៅតែចាប់ផ្ដើមផ្ទាំងទី៨ទៀត ... តើបងគូរឱ្យនរណាក៏ច្រើនម្ល៉េះ ?

– សម្រាប់ពិពណ៌ ដែលជប៉ុនគេនឹងធ្វើនៅពេលឆាប់ៗ នេះ !



បងត្រូវតែខំសាងឈ្មោះបង ទោះបីពុំបានកម្រៃប៉ុន្មានក៏ដោយ !

– បើអញ្ចឹងនាំអូនទៅដើរលេងទៅ

– កុំបង្ខំបង !

– ស្អី. អូនបង្ខំបងឯង ? មួយអាទិត្យក្រោយពីការរង់ចាំរបស់អូនដ៏អន្ទះអន្ទែង នៅក្នុងរោងជាងដ៏ក្រខ្វក់នេះ. ដោយបែកញើសជោកខ្លួនហើយ ដែលឥតហ៊ានទៅណាសោះ ! ទីបំផុតរង្វាន់ដែលអូនបានទទួលពីបង គឺសម្ដីដ៏អាក្រក់ឃោរឃៅ ដូច្នេះឬ ? គ្មានពាក្យទន់ភ្លន់សោះ ? អូនតែងអភ័យទោសឱ្យបងជានិច្ច ពីព្រោះអូនយល់ថាសិល្បករស្រឡាញ់សិល្បៈរបស់ខ្លួន ។ អូនធ្លាប់អានសៀវភៅឃើញស្រីម្នាក់ដែលស្រឡាញ់គូសង្សាររបស់ខ្លួន សុខចិត្តស្រាតទាំងអស់អង្គុយលើកៅអីមួយដើម្បីឱ្យសង្សារនោះគូរ ។ ម្នាក់ៗ ក៏សុទ្ធតែជោកជាំក្នុងសិល្បៈដូចគ្នា ។ បុរសជាសង្សារខិតខំសំអិតសំអាងគូររូបនារីជាសង្សារ ។ នារីជាសង្សារទ្រាំអង្គុយមិនហ៊ានកម្រើកដើម្បីឱ្យបុរសជាសង្សារគូរ. ពេលវេលាកន្លងទៅអស់៣យប់៣ថ្ងៃ ដោយម្នាក់ៗ ឥតឃ្លាតពីករណីកិច្ចរបស់ខ្លួនឡើយ ហើយម្នាក់ៗ ភ្លេចបរិភោគបាយទាំងអស់គ្នា ។ ក៏ប៉ុន្តែបុរសជាគូរសង្សារ ដែលគេមាន

ចលនាដៃទីងជើងនោះឈោមឥតស្លាក់ឡើយ ។ ទីបំផុត. នៅពេលដែលគេគួរនិងផាត់ផ្ទាំងគំនូរ រួចហើយស្ទុះទៅកេះសង្សារដើម្បីមកមើលសរសើររូបផ្ទាំងគំនូរនេះទាំងអស់គ្នា ។ អនិច្ចា ! នារីជាសង្សារក៏ដួលត្លុង ... នាងស្លាប់ព្រោះស្លាក់ឈាម ដោយឥតកម្រើកទាល់តែសោះ ...

វិចិត្របែរមើលមុខខ្ញុំ ហើយឥតមានមនោសញ្ចេតនាអ្វីសោះ ។ តាមពិតបើពេលធម្មតាវិញ. វិចិត្រជាមនុស្សដែលមានសេចក្តីរំភើបណាស់ កាលបើដឹងរឿងរ៉ាវដូច្នេះ. ក៏ប៉ុន្តែឱ្យតែគាត់កាន់ជក់គូររូបហើយក្នុងលោកនេះគ្មានអ្វីធំជាងរូបគំនូររបស់គាត់ទេ ។ សូម្បីខ្ញុំនេះក៏ដោយ ...

ឥរិយាបថរបស់គាត់ដូច្នេះ គឺជាការប្រមាថចំពោះខ្ញុំ. ជានារីដែលសាហាវដូចពស់វែកនេះដែរ ។ ខ្ញុំបោះសំដីដ៏ក្តៅក្រហាយថា ÷

– នែ ! លោកសិល្បករ. ខ្ញុំមិនអាចទ្រាំបាននឹងការ សោះអង្គើយរបស់លោកបានទេ ។ ខ្ញុំសូមសួរបញ្ជាក់លោកនៅពេលនេះថាតើលោកទៅឬមិនទៅជាមួយខ្ញុំ ?

បងវិចិត្រនៅស្ងៀមដដែលឥតកម្រើក ។ ខ្ញុំផ្ទួនសំណួរជាលើកទីពីរ ។ រួចជាលើកទីបី ...



ខ្ញុំបោះជំហានដើរចេញដោយសំដៅមាត់ទ្វារ. ទៅដល់មាត់ទ្វារខ្ញុំកាន់ក្បាលត្រមោង ហើយខ្ញុំបើកទ្វារ ក៏ប៉ុន្តែខ្ញុំងាកក្រោយដោយខ្ញុំដឹងច្បាស់ថាគ្រប់ៗគ្រា ដែលខ្ញុំចេញទៅ បងវិចិត្រតែងតែងាកមុខមកញញឹមដាក់ខ្ញុំ ។ ប៉ុន្តែម្តងនេះខុសស្រឡះ បងវិចិត្រឥតងាកចេញពីផ្ទាំងគំនូររបស់គាត់ឡើយ ។ ខ្ញុំបើកទ្វារហើយខ្ញុំចេញពាក់កណ្តាលខ្លួនដោយបែរមុខមកខាងក្នុងផ្ទះ ។ បងវិចិត្ររក្សាឥរិយាបថដើមឥតកម្រើកដដែល ។ ខ្ញុំបិទទ្វារគ្រឹបហើយខ្ញុំចុះជណ្តើរ ។

នៅពេលដែលខ្ញុំដើរមកដល់ថ្នល់. កាលពីដើម. បងវិចិត្រឈរមើលខ្ញុំតាមបង្អួច ។ ម្តងនេះបង្អួចឥតរបើកសោះ ។ សេចក្តីក្តៅក្រហាយដែលខ្ញុំមានស្រាប់មកហើយនោះ ក៏ឆេះដង្គោលឡើងបីដូចជាអគ្គីភ័យ ។ ថ្ងៃរណោះម៉ោង៧យប់ទៅហើយ. គួរណាស់តែបងវិចិត្រយករថយន្តរបស់គាត់ជូនខ្ញុំទៅផ្ទះវិញ ។ ក៏ប៉ុន្តែបងវិចិត្រថ្ងៃនេះពុំដូចជាបងវិចិត្រកាលពីអាទិត្យមុននោះទេ ។ តើបងវិចិត្រលែងស្រឡាញ់ខ្ញុំឬ ? ឬមួយក៏បងវិចិត្ររវល់មែន ?

សេចក្តីក្តៅក្រហាយរបស់ខ្ញុំ ពុំអនុញ្ញាតឱ្យខ្ញុំគិតអ្វីក្រៅពីយក

កំហឹងមកដាក់ក្នុងបេះដូងនោះឡើយ ។ ជាការពិតណាស់ថាខ្ញុំជានារីមួយរូប ហើយកាលបើខ្ញុំប្រគល់កាយទៅឱ្យគេហើយ ជាការធម្មតាទេ. បុរសនោះត្រូវតែធុញទ្រាន់នឹងខ្ញុំ ។ ខ្ញុំជាចំពូកស្រីដែលទុំមុនស្រគាល ហើយខ្ញុំជាស្រីមួយរូបពុំចេះទប់ចំណង់នៃកាមតណ្ហារបស់ខ្ញុំបានឡើយ ។ ពិតហើយពាក្យសុភាសិតបារាំងមួយ ពោលថា "ស្រីនិយាយជាមួយបុរសទី១. លួចមើលបុរសទី២. ហើយនឹកគិតដល់បុរសទី៣" "La femme Parle avec le premier homme, regarde le deuxième et pense au troirsième"

ប៉ុន្តែនិយាយដោយត្រង់ទៅ. មុនពេលដែលខ្ញុំបានស្គាល់បងវិចិត្រ. ខ្ញុំដើរលេងខ្លះមែន ប៉ុន្តែពុំដែលហួសគន្លងប្រពៃណីម្តងណាឡើយ ។ ហើយបុរសទី១ នៃជីវិតរបស់ខ្ញុំដែលបានហែកហួរដួងចិត្តខ្ញុំនោះ គឺគ្មាននរណាក្រៅពីបងវិចិត្រនេះឡើយ ... តើបងវិចិត្រគេធុញទ្រាន់នឹងខ្ញុំមែនឬ ? គ្មានបញ្ហាអ្វីចោទ ឡើយចំពោះខ្ញុំជានារីមួយរូបដែលស្គាល់អារ្យធម៌ ។

# ២

# ក្តីបារម្ភ

នៅពេលដែលវិចិត្រផាត់ពណ៌គំនូររបស់ខ្លួនរួចហើយ. អ្នកក៏ងាកក្រោយដើម្បីរកមើលសង្សារ ។ កន្ធី បានចេញផុតទៅហើយ ? កាលពីមុនកន្ធីធ្លាប់និយាយថា "អូនលាបងហើយ" ក៏ប៉ុន្តែកន្ធីឥតទៅណាសោះ ; កន្ធីអង្គុយនៅឯសាឡុងខាងក្រៅរង់ចាំអ្នកដដែល ។ ម្តងនេះកន្ធីទៅមែន ... អ្នកមានសេចក្តីសោកស្តាយណាស់ ដែលមិនបានជូននាងទៅ. ក៏ប៉ុន្តែអ្នកមានបំណង ចង់បង្ហើយផ្ទាំងគំនូរនេះដែរ ។ កាលណាថ្នាំស្ងួតគេពុំអាចបំផ្លែងពណ៌ទៅតាមបំណងបានឡើយ ។ សិល្បករ. ជាការធម្មតាទេ ដែលប្រពន្ធរបស់ខ្លួនជិតជានិច្ចសិល្បករ. គ្មានយកចិត្តទុកដាក់អ្វីខ្លាំងក្រៅអំពីសិល្បៈរបស់ខ្លួនទេ.

ហើយគេ តែងឃើញសិល្បករជាច្រើន ដែលទទួលការអភ័ព្វណាស់ក្នុងវិស័យស្នេហា ...

មែន ! មែន ! វិចិត្រពុំបានតាំងខ្លួនជាសិល្បកររហូតដល់ទៅភ្លេចបាយភ្លេចទឹក ហើយជាពិសេសគឺភ្លេចសង្សារកន្និរីសម្លាញ់នោះឡើយ ... តើហេតុ អ្វីបានជាអម្បាញ់មិញនេះ អ្នកមានឬកពារប្រឡើសបើសដាក់គេដូច្នេះ ? វិចិត្រក៏ពុំយល់ចំពោះខ្លួនឯងដែរ ។ មែន ! ចរិតលក្ខណៈមនុស្សមានពេលខ្លះគេពុំអាចពណ៌នាបានដូច្នោះមែន ។

អ្នកសង្ឃឹមច្បាស់ថា. បន្តិចទៀតកន្និរីនឹងវិលត្រឡប់មករកអ្នកវិញ ហើយគេទាំងពីរនឹងបានដើរក្រសាលតាមដងទន្លេ ឬតាមវិថីនានានៃទីក្រុង ។ កន្និរីខឹងមិនយូរទេ ... ខឹងក៏មិនប្រវែងណាដែរ !

គិតទៅពេលវេលាកន្លង១ម៉ោងហើយ តែនាងឥតលេចស្រមោលមកវិញសោះ ។ ទីបំផុតអ្នកក៏ដើរទៅកាន់ទូរស័ព្ទហើយក៏វាវៃលេខផ្ទះរបស់កន្និរី ...

— អាឡូ ... កន្និរីឬ ? វិចិត្រសួរនៅពេលដែលឮដៃទូរស័ព្ទឯម្ខាង ឯណោះត្រូវគេលើកឡើង ។



សម្លេងដ៏ផ្អារមួយទៀតឆ្លើយតបមក. ដោយរីករាយដែរ:

— មិនមែនទេ. នរណាហ្នឹងសម្លេងដូចជាវិចិត្រមែនទេ ?

— ពិតហើយអ្នកបងវេខា ។ កន្និរីទៅដល់ផ្ទះហើយឬនៅបង ?

វេខាជាបងស្រីរបស់កន្និរី ។ នាងធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយក្នុងទីក្រុង ។ ដោយបានអប់រំនាងកន្និរីតាំងពីតូចមក ។ កន្និរីនេះមានការកោតគោរពបងស្រីដូចជាម្តាយ ពីព្រោះអ្នកទាំងពីរនេះកំព្រាឪពុកម្តាយតាំងពីក្មេងដូចគ្នា ។

— វិចិត្រ ; កន្និរីមកដល់ផ្ទះមួយភ្លែត ហើយស្រាប់តែប្រាប់ខ្ញុំថា "អ្នក បង ! ខ្ញុំសុំទៅមើលកុនហើយ !" ថាប៉ុណ្ណេះកន្និរីក៏ចេញទៅ ។

— ម៉េចក៏អ្នកបងបណ្តោយឱ្យកន្និរីទៅតែម្នាក់ឯងដូច្នោះ ?

— ព្រោះខ្ញុំកំពុងរវល់កែកិច្ចការកូនសិស្ស ។ កន្និរីប្រហែលជាធុញទ្រាន់គ្មាននរណានិយាយជាមួយក៏មិនដឹងស្រាប់តែទៅបាត់ដោយខ្ញុំមិនទាំងបានដឹង ខ្លួនផង ។ ខ្ញុំទើបតែដឹងអម្បាញ់មិញនេះ !

— ទៅមើលកុននៅរោងណាបង ?

— នាងប្រាប់ខ្ញុំថាទៅមើលរឿងនៅឯរោងកុនបូកគោ ...

ទីបំផុតការសន្ទនាតាមទូរស័ព្ទនេះក៏ចប់ ។ វិចិត្រវេរាក្នុងចិត្ត

បន្ទិច ។ ការទៅរកមនុស្សម្នាក់នៅក្នុងរោងកុនពុំមែនជាការងាយស្រួលនោះទេ. ដូច្នេះអ្នកត្រូវតែស្ថិតនៅក្នុងផ្ទះរបស់អ្នកដើម្បីធ្វើការបណ្ដើរ និងរង់ចាំបណ្ដើរ ។ តែពីរម៉ោងប៉ុណ្ណោះភាពយន្តនឹងចប់ហើយដប់នាទីប៉ុណ្ណោះ. កន្ធីរនឹងមកដល់ផ្ទះគឺនៅម៉ោង៩និង១០នាទី. អ្នកនឹងរវៃទូស័ព្ទទៅជាថ្មីម្ដងទៀត ...

វិចិត្រហាក់ដឹងថាអ្នកដូចជាមានចិត្តធីងធោងជាខ្លាំង នៅពីមុខផ្ទាំងគំនូរថ្មីមួយទៀត ដែលអ្នកទើបតែចាប់ផ្ដើមផាត់ពណ៌នេះ ។

ពេលវេលាកន្លងទៅរហូតដល់ម៉ោង ៩និង១៥នាទី. រួចម៉ោង៩កន្លះ ។ វិចិត្រក៏លើកទូរស័ព្ទវៃលេខជាថ្មីឡើង ដើម្បីហៅកន្ធីរនៅគេហដ្ឋានរបស់នាង ទីបំផុតគឺសម្លេងរបស់រេខាទេដែលនិយាយមកថា ÷

– កន្ធីរមិនទាន់មកដល់ផ្ទះវិញសោះ. វិចិត្រ. ខ្ញុំឆ្ងល់ណាស់ហេតុអ្វីក៏យូរដូច្នេះ ?

## ៣

## អន្ទាក់ចៃដន្យ

ពីរម៉ោងនៅក្នុងការទស្សនាខ្សែភាពយន្តផ្នែកសោកនាដកម្មនេះកាន់តែ បណ្ដាលឱ្យខ្ញុំមានសេចក្ដីក្ដៅក្រហាយថែមទៀតចំពោះបុរសខ្ញុំជាស្រីដែល កំពុងតែមានគំនុំគុំគួនស្រាប់ផងនោះ ឥឡូវមកមើលប៉ះរឿងមួយដែលជារឿងសោកនាដកម្មដ៏សែនឈឺចាប់ ។ នៅពេលចេញពីរោងភាពយន្ត. ខ្ញុំគេចខ្លួនទៅឈរនៅជ្រុងម្ខាង ហើយខ្ញុំងើយមើលទៅលើមេឃ ព្រះច័ន្ទរះក្រឡង់នៅកណ្ដាលហ្វូងតារា. ខ្យល់បក់ល្ហៀកៗ ។

ស្រាប់តែមិនដឹងជាចៃដន្យអ្វី. អារម្មណ៍របស់ខ្ញុំបានញ៉ាំងចិត្តខ្ញុំឱ្យចង់ដើរ ។ លំនៅស្ថានរបស់បងស្រីខ្ញុំស្ថិតនៅវិថីប្រជាធិបតេយ្យ

ហើយពុំសូវជាឆ្ងាយពីទីនេះប៉ុន្មានទេ មនុស្សម្នាក់នៅតែមានធ្វើដំណើរគោចរទៅវិញទៅមកទាំងស្រីទាំងប្រុសហូរហែដែរ ។ ខ្ញុំឈរនៅឯជ្រុងងងឹតបន្តិចដោយចិត្តមួរហ្មង. ហើយហាក់ដូចជាពុំទាន់មានបំណងចង់ទៅផ្ទះវិញភ្លាមៗ ទេ ។ កំហឹងរបស់ខ្ញុំឆេះឆួលយូរណាស់ ។ តែប៉ុន្មាននាទីក្រោយមក មនុស្សម្នាវិលទៅលំនៅស្ថានស្ងាត់អស់. ខ្ញុំក៏បោះជំហានចេញមក ។ ក្នុងមួយខណៈនោះ. ខ្ញុំឮសម្រែកមួយ. ហើយខ្ញុំក៏ងាកក្រោយ ។ តើខ្ញុំឃើញទស្សនីយភាពអ្វី ? គឺស្ត្រីចាស់ម្នាក់ដែលដួលហើយខ្ញុំឃើញតាចាស់ជាប្ដី កំពុងតែស្ទុះទាំងទទីទទាជួយលើកភរិយារបស់ខ្លួន ។ តាំងពីដើមរៀងមក. ខ្ញុំជានារីមានពូជអម្បូរ ហើយតែងតែយកចិត្តទុកដាក់ក្នុងការជួយអ្នកដទៃជានិច្ច ។ ឃើញស្ត្រីចំណាស់មួយរូបដែលដួលដោយភ្លាត់ជើងដូច្នេះ. ខ្ញុំក៏ស្ទុះទៅជួយគ្រាហ៊ាជាមួយតាចាស់នោះ ។ ស្ត្រីចាស់ក៏ក្រោកឈរឡើង. ចំណែកឯតាចាស់ជាប្ដីក៏មានការស្រយុតស្រយង់ជាខ្លាំង ។ ខ្ញុំឃើញបបូរមាត់គាត់ញ័រៗ ភ្នែករបស់គាត់បិទបើកម៉ក់ៗ ។

– ម៉េចយាយបុិឥតឈឺចាប់អ្វីទេឬ ?

ស្ត្រីចំណាស់នេះដកដង្ហើមបន្តិច ហើយក៏និយាយក្នុងភាពងងឹតនៅមុខ រោងភាពយន្តដែលគេទើបនឹងបិទភ្លើងនេះ ដោយពាក្យមួយៗ ថា ÷



– ខ្ញុំមិនបានដឹងដែរ. មិនដឹងជាវាឈឺចាប់ឬគ្រេចត្រង់ណាឡើយ ...

ស្រីចំណាស់នេះ បោះជំហានទៅមុខហើយស្រាប់តែទ្រេតចង់ដួល រួចទ្រេតខ្លួនមកកាន់ស្មាខ្ញុំដើម្បីទប់ ។

– ឱព្រះអើយ ! ស្ត្រីចំណាស់នេះស្រែកឡើង ។

ខ្ញុំគ្រេច-កជើងហើយ ។ អែយ៉ូយឈឺម្ល៉េះ !

តាចាស់ក៏មកជួយគ្រាហ៊ាភរិយាខ្លួននៅម្ខាង. ហើយដោយឃើញភាព ទទ្រេតទទ្រោតដូច្នេះ ខ្ញុំក៏មិនទាន់លះបង់តាចាស់យាយចាស់ដែលមានភាពដូចឪពុកម្ដាយខ្ញុំនេះទេ ។ ម្យ៉ាងទៀតខ្ញុំពុំដែលរស់នៅក្រោមសេចក្ដីថ្នាក់ថ្នម របស់មនុស្សចាស់ណាម្នាក់ទាល់តែសោះ ។ ការដែលបានជួយស្រោចស្រង់គេ មួយរយៈកាលដូច្នេះ បណ្ដាលឱ្យទឹកចិត្តខ្ញុំរីករាយ ហើយជំនោរនៃសេចក្ដីល្អ របស់ខ្ញុំមិនទាន់ធ្លាក់មកសណ្ឋិតទៀតនៅឡើយទេ ។ ខ្ញុំក៏និយាយឡើងថា ÷

– អ៊ំស្រីអញ្ជើញកាន់ដៃខ្ញុំមក ខ្ញុំនឹងជួយទប់អ៊ំស្រី ហើយបន្តិច

ទៀត ស៊ីក្លូមកដល់អ៊ំស្រីអាចអញ្ជើញបាន ។

– ទេ. ទេ. ទេ. តាចាស់និយាយ ។ យើងមានឡានមួយនៅមិនឆ្ងាយពីទីនេះប៉ុន្មានទំនង ! តាចាស់ជាប្ដីចង្អុលទៅឡានខ្មៅយង់មួយដែលចតនៅពីក្រោមដើមឈើ ។ បន្ទាប់មកស្រីចំណាស់នេះក៏និយាយយ៉ាងទន់ភ្លន់ថា ÷

– ក្មួយស្រី. ក្មួយស្រីអាចទៅជាមួយអ៊ំបាន ។ អ៊ំទាំងពីរនឹងជូនក្មួយស្រីទៅដល់ផ្ទះ ។ ប៉ុន្តែអ៊ំសុំពឹងក្មួយបន្តិចគឺថា ក្មួយស្រីត្រូវទៅផ្ទះអ៊ំមួយភ្លែតសិន ដោយគ្រាន់តែជួយគ្រាហ៍អ៊ំឱ្យចុះពីឡាននិងចូលក្នុងផ្ទះប៉ុណ្ណោះ ។ បន្ទាប់ពីនេះ អ៊ំប្រុសអាចនឹងបើកឡាននេះជូនក្មួយត្រឡប់ទៅផ្ទះវិញភ្លាម ។ តែ ៥ឬ៧នាទីប៉ុណ្ណោះ ។ អ៊ំមានតែប្ដីប្រពន្ធពីរនាក់ប៉ុណ្ណោះ ។

តើមានអ្វីជាឧបសគ្គចំពោះរូបខ្ញុំ ក្នុងការជួយគ្រាហ៍ស្ត្រីម្នាក់នេះហើយដែលប្ដីរបស់គាត់ក៏ចាស់ដែរ ពុំអាចបំពេញភារកិច្ចនេះបានតែម្នាក់ឯង ? ការជួយអ្នកដទៃមួយភ្លែត រួចត្រលប់មកផ្ទះវិញក៏ឈ្មោះថាសប្បុរសធម៌មួយដែរ ។ ណាមួយខ្ញុំចង់ធ្វើអំពើមួយ ដើម្បីបំភ្លេចសេចក្ដីឈឺចាប់របស់ខ្ញុំចំពោះបងវិចិត្រទៀតផង ។ ខ្ញុំក៏ឡើងរថយន្ត



នេះ ។ គឺជារថយន្ត CITROEN ពណ៌ខ្មៅ ។ ក្នុងពេលដែលម៉ាស៊ីនវាឆេះរថយន្តនេះក៏ញ័រអស់ទាំងតួ ។ រថយន្តក៏ចេញទៅ ...

ខ្យល់ផាត់ចូលមកតាមទ្វាររថយន្ត. ត្រជាក់ស្រឹតដល់ដួងតម្រិលក្នុងមួយរំពេចនោះស្រាប់តែខ្ញុំភ្ញាក់ខ្លួនឡើង ហាក់បីដូចជាភ្ញាក់ពីស្ថានសុបិនដូច្នោះ ... យី ! តើខ្ញុំទៅណា ? ប៉ុន្តែពេលនេះជ្រុលហួសហើយ. រថយន្តកំពុងតែបោលទៅមុខ ។ តាមរស្មីអគ្គិសនីដែលជះពីដងគោមមកម្ដងៗ នោះដោយចៃដន្យ. ខ្ញុំចោលភ្នែកមើលទៅអ្នកបើកបររថយន្ត ។ គាត់នេះប្រកាន់ឥរិយាបថស្ងៀមហើយហាក់ដូចជាឥតគិតគូរអ្វីក្រៅតែពីមើលផ្លូវនោះឡើយ ។ នេត្ររបស់ខ្ញុំគាប់ជួនប្រទះលើដៃរបស់គាត់ទាំងពីរ ដែលកំពុងកាន់ចង្កូតរថយន្ត។ វេទនារម្មណ៍មួយក៏ផុះឡើង ដែលធ្វើឱ្យខ្ញុំរញ្ជួយអស់ទាំងកាយា ។ ក៏ប៉ុន្តែជ្រុលពេលទៅហើយ. រថយន្តកំពុងតែបោលទៅមុខ ... រថយន្តបត់បែនជាច្រើន កន្លែងហើយខ្ញុំហាក់ដូចជាវង្វេងអស់ពុំដឹងថាទីណាទៀតផង. ផ្លូវស្ងប់ស្ងាត់ហើយវែងសន្ធឹងទៅមុខលន្លង់លន្លោច ។ ក៏ប៉ុន្តែទោះបីយ៉ាងណាក្ដី ខ្ញុំនៅតែជឿថានេះជាក្រុងភ្នំពេញ ព្រោះយានរត់មិនទាន់បានដប់នាទីផងទេ ...

ក្នុងពេលនោះស្គូរក្រដាសទង្គិចគ្នាយ៉ាងស្ងួត  រួចខ្ញុំបែរទៅស្ត្រីចាស់ ។ ស្ត្រីចំណាស់ក៏និយាយដោយទន់ភ្លន់ថា ÷

–. ក្មួយស្រី ខ្ញុំបានទិញគ្រាប់ស្កូរនេះកាលពីថ្ងៃ ។ ក្មួយស្រីក៏ដឹងដែរថា មនុស្សចំណាស់ខ្ញុំទាំងប្ដីខ្ញុំទាំងរូបខ្ញុំ បែរទៅជាមានបំណងចង់បរិភោគស្ករ ដូចកាលដែលយើងនៅយុវវ័យដូចក្មួយស្រីដូច្នោះឬ !

ខ្ញុំស្រឡាញ់ណាស់គ្រាប់ស្ករនេះ  ។  ម្យ៉ាងទៀតខ្ញុំហាក់ដូចជាមានការរំជើបរំជួលជាខ្លាំង  តាំងពីល្ងាចមិញម្ល៉េះបន្ទាប់ពីមានរឿងរ៉ាវជាមួយបងវិចិត្រមក ។ គ្រាប់ស្ករគឺឱសថម្យ៉ាងសំរាប់រម្ងាប់ការរញ្ជួយចិត្តដូចជាពេលឡើងជិះយន្តហោះ. គេតែងតែចែកស្ករនេះដល់អ្នកដំណើរ ។ រំលឹកឃើញរឿងនេះខ្ញុំក៏ ទទួលគ្រាប់ស្ករពីស្ត្រីចំណាស់ដោយឥតរារែកឡើយ ។ ស្ត្រីចាស់ក៏រលាស់សំណួរថា ÷

– ក្មួយស្រីនៅឆ្ងាយពីទីនេះមែនទេ ? តែម្នាក់ឯងមែនទេ ?

– ទេ. ខ្ញុំនៅមិនឆ្ងាយពីរោងកុនបូកគោប៉ុន្មានទេ. ខ្ញុំរស់នៅជាមួយបងស្រីខ្ញុំជាគ្រូបង្រៀនម្នាក់. អ៊ំស្រី. មិនយូរប៉ុន្មានទេប្រហែលជាខែក្រោយនេះខ្ញុំនឹងរៀបការជាមួយបងវិចិត្រ ។

ក្នុងភាពងងឹតព្រិលៗ នៃរថយន្ត. ខ្ញុំឃើញនេត្រាស្ត្រីនេះសម្តែង



សេចក្ដីរីករាយ ។ ក្នុងមួយរំពេច. ខ្ញុំហាក់ដូចជាភ្លេចអ្វីៗ ទាំងអស់ ហើយខ្ញុំបានឮស្ត្រីចំណាស់និយាយកម្លាចិត្តខ្ញុំថា ÷

– ជាការប្រសើរណាស់  ដែលគេបានប្រព្រឹត្តយុវវ័យឱ្យកន្លងទៅនៅក្នុងក្របខ័ណ្ឌប្រពៃណី ! យុវជននិងយុវនារីនាសម័យនេះ. ពុំសូវបានស្គាល់អត្ថន័យ  ជាក់ច្បាស់អំពីទំនៀមទំលាប់នេះទេ ... ភាគច្រើនសុទ្ធតែជ្រុលខ្លួន. មិនថាអ៊ីចឹងតាបុ ? កាលជំនាន់យើងពីដើមម្ដាយឪពុកចាប់គ្នារៀបការមង្គលការមាន អីគេចេះតែស្រឡាញ់គ្នាដូច្នោះទៅកើតដែរ ! ប៉ុន្តែយុវជនសម័យនេះពុំអាចធ្វើជាគ្រឿងឧបករណ៍នៃស្នេហាបានទេ  ។  ក៏ប៉ុន្តែការដែលជួបគ្នាក្នុងប្រពៃណីទំនៀមទំលាប់គឺជាការមួយគួរឱ្យសរសើរណាស់. មិនថាអ៊ីចឹង ?

ខ្ញុំអរព្រួចក្នុងចិត្ត ហើយផ្អែកទៅលើបង្អែកនៃរថយន្ត ។ ស្ត្រីចាស់បន្ថែមសំដីថា ÷

– តែ ៣-៤ នាទីទៀតទេក្មួយស្រី. ក្មួយស្រីនឹងបានត្រឡប់ទៅផ្ទះវិញហើយ ...

ខ្ញុំភ្ញាក់ស្រឡាំងកាំងដោយរថយន្តឈប់ភ្លាម ។ ខ្ញុំទើបតែនឹងដឹងថារថយន្តនេះបានចូលមកក្នុងផ្លូវមួយមានភ្លើងបំភ្លឺព្រឿងៗ ប៉ុណ្ណោះ.

ល័យ ហ៊ុន សែន

ដោយសារ ចង្កៀងគោមជំនាន់បូរាណមួយដែលបញ្ឈរនៅឯជញ្ជាំង នៅពីខាងក្រោយ ខ្ញុំគឺជាផ្លូវចាក់កៅស៊ូមួយហើយដែលខ្ញុំពុំដឹងថាផ្លូ នោះឈ្មោះផ្លូវអ្វីផង ។ ទីនេះគឺជាច្រកដែលបន្តពីផ្លូវធំមកហើយមក ទាល់ត្រង់របងចម្រឹងដែកដ៏ស្រួចហើយខ្ពស់នៃវិមានមួយ ។ ទីនេះ ងងឹត. តាចាស់ក៏ចុះពីរថយន្តរួចដកកូនសោរពីហោប៉ៅ ហើយបើក ទ្វារចម្រឹងដែក រួចត្រឡប់មកកាន់រថយន្តវិញ ។

ខ្ញុំបែរក្បាលទៅក្រោយ ហាក់ដូចជាដើម្បីមើលវិថីចាក់កៅស៊ូ នោះម្តងទៀត. ក៏ប៉ុន្តែករបស់ខ្ញុំហាក់ដូចជារឹង. តើកើតហេតុអ្វី ? រួចត្រចៀករបស់ខ្ញុំហាក់ដូចជាហ៊ឹង. ហើយខ្ញុំឮសូរសម្លេងល្វើយៗ ÷

– ក្មួយស្រីអញ្ជើញចុះ !

– ចាំះ. អ៊ំស្រី. ខ្ញុំឆ្លើយតបទៅទាំងហេវហត់ជាខ្លាំង ។

តើខ្ញុំកើតអ្វីក្នុងខ្លួនខ្ញុំ ដែលកាលពីមុននេះដប់នាទីខ្ញុំមានសុខ-ភាពពេញខ្លួនទាំងអស់ ? ទ្វារឡានចំហរដោយតាចាស់ ខ្ញុំហាក់ដូច ជាពុំដឹងថាខ្ញុំដាក់ជើងទៅលើដីទៀតផង ។ ខ្ញុំងើយក្បាលឡើងលើ ដើម្បីស្រូបយកដង្ហើមថ្មីនាពេលរាត្រី ។

នៅពេលដែលខ្ញុំឈរ. ស្រាប់តែមួយរំពេចនោះខ្ញុំដួលប្រួសទៅ

KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង គាំទ្រសិល្បៈអក្សរសាស្ត្រខ្មែរ

លើដី ។ យីហេតុអ្វីដូច្នេះ ? នៅជុំវិញខ្លួនខ្ញុំអ្វីៗវិលខ្វាល់ទាំងអស់ ។

នៅពេលដែលតាចាស់ ជួយគ្រាហ៍ខ្ញុំក្រោកឈរឡើងនោះ. ក្នុង ពេលនោះ. ឯងខ្ញុំបានឮសូរសម្លេងរថយន្តមួយបើកបរ នៅឯផ្លូវចាក់ កៅស៊ូខាងក្រោយខ្នងខ្ញុំ ។ បេះដូងរបស់ខ្ញុំរំជើបរំជួលយ៉ាងចម្លែក បំផុត ។ បងវិចិត្រ ! សូររថយន្ត នេះទោះបីជាបន្លឺនៅក្នុងចំណោម រថយន្ត ១000 ទៀតក៏ខ្ញុំឥតច្រឡំដែរ ! សេចក្តីនឹករឭកដល់រឿង ចាស់. ដល់រឿងស្នេហារបស់ខ្ញុំក៏លុកទន្រ្ទានក្នុងដួងចិត្តថា "បងវិចិត្រ ប្រហែលជាបើករថយន្តតាមរកខ្ញុំ ។ ខ្ញុំបង្ហើយកិច្ចការឥឡូវ ខ្ញុំនឹង បានត្រឡប់ទៅផ្ទះវិញហើយ ..."

បង្ហើយកិច្ចការស្អី ? ខួរក្បាលរបស់ខ្ញុំចាប់ផ្តើមវិលជាថ្មី ហើយ ខ្លាំងជាងមុនទៀតផង ។ ខ្ញុំលែងគិតឃើញក្នុងការជួយសង្គ្រោះអ្នក ណាទាំងអស់. យាយចាស់គោងស្វាប្តីគាត់ដើរប៉ាច់ពៀចៗ ទំនងជា គ្រេចភ្នែកគោលមែន ។

ក៏ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ខ្ញុំឮសម្លេងដែលស្ត្រីនិយាយ ហាក់បីដូចជាឆ្ងាយល្វើយអើយសែនល្វើយ ÷

– ស្រេចហើយបង ... នាងស្រីនេះធន់បានយូរណាស់ ...

អាថិកំបាំងក៏របើកឡើងភ្លាមមួយរំពេច ។ សេចក្ដីតក់ស្លុតមួយដែលពុំអាចទ្រាំទ្របានចូលមកប្រាប់បេះដូងខ្ញុំ ។ ភ្លាមមួយរំពេចនោះឯងខ្ញុំបាត់បង់អស់ក្នុងឋានៈខ្ញុំជាម្ចាស់នៃចលនានៃរាងកាយខ្ញុំ ។ ខ្ញុំដឹងច្បាស់ណាស់ថាខ្ញុំត្រូវគេដាក់ថ្នាំសណ្ដំ ។ ដោយខ្ញុំធ្លាប់អានប្រលោមលោកផ្នែកខាងប៉ូលីសនិងចារកម្ម ជាច្រើនខ្ញុំក៏នឹកឃើញថា "នេះគឺជាកលល្បិចជំនាន់បូរាណ ។ គេសុំឱ្យស្ត្រីម្នាក់ជួយគេពីរឿងអ្វីមួយដែលខានពុំបានហើយគេក៏អញ្ជើញនាងឱ្យទទួលការជិះ រថយន្តរបស់គេរួចគេផ្ដល់ទឹកភេសជ្ជៈឬគ្រាប់ស្ករតាមការគួរ ។ បន្ទាប់មកនាងក៏ប្រគល់ខ្លួនទៅឱ្យសត្រូវរបស់នាង ដោយឥតមានអ្វីការពារខ្លួនសោះឡើយ ..."

ប៉ុន្តែទោះបីយ៉ាងនេះក្តី ខ្ញុំហាក់ដឹងថាខ្ញុំកំពុងតែបោះជំហានដើរម្តងនេះពុំមែនខ្ញុំទេដែលគ្រាហ៍យាយចាស់. គឺយាយចាស់ឯណោះទេដែលគ្រាហ៍ខ្ញុំវិញ ។ មែនខ្ញុំទើបតែនឹកឃើញថា ក្នុងពេលដែលរថយន្តកំពុងរត់តាមដងវិថីនោះ ដោយពន្លឺចង្កៀងអគ្គិសនីជះមកម្តងៗ នោះខ្ញុំរំលឹកឃើញថា ខ្ញុំបានឃើញដៃរបស់តាចាស់អ្នកបើកបរ មែនខ្ញុំបានពិនិត្យឃើញថា គឺជាដៃរបស់បុរសនៅក្មេងនៅឡើយ !



ដោយខ្ញុំបានដឹងរឿងអកុសលរបៀបនេះ តាមប្រលោមលោកផ្នែកប៉ូលីស និងចារកម្មជាច្រើនរឿង. ខ្ញុំខំយកជំនះខាងផ្លូវចិត្តរបស់ខ្ញុំ កុំឱ្យទ្រុឌទ្រោមទៅតាមអនុភាពនៃថ្នាំ ។ ខ្ញុំបង្កើនសេចក្ដីក្លាហានថ្វីត្បិតតែកម្លាំងរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅៗ ក៏ដោយ ។ ខ្ញុំមិនបើកភ្នែកទេ ក៏ប៉ុន្តែខ្ញុំដឹងនូវអ្វីៗ ទាំងអស់ដែលកើតឡើងជុំវិញខ្ញុំ ។ បុរសស្ត្រីក៏នាំខ្ញុំចូលក្នុងផ្ទះពេលនេះ ។ ខ្ញុំគ្មានសមត្ថភាពដើម្បីរត់ទៅឡើយ ... ខ្ញុំមានតែព្រងសំណាងតែម្យ៉ាងប៉ុណ្ណោះ. ព្រងសំណាងម្យ៉ាងប៉ុណ្ណោះ ...

ខ្ញុំឮសម្លេងល្វើយៗ ដែលគេពោលមកកាន់ខ្ញុំ ÷

– ម្តងនេះស្រេចហើយ. នាងលែងធន់បាននឹងកម្លាំងថ្នាំនេះហើយ ...

– ស្រីនេះស្អាតណាស់. សម្លេងបុរសអ្នកបើកបរឆ្លើយតប ។ ស្អាតម្ល៉េះព្រះអើយ ... ខ្ញុំកម្ររកឃើញស្រីដែលមានសោភ័ណភាពដូច្នេះណាស់ ។ នាងនេះមានកាយដូចទេវនារី. នេត្រាភ្លឺថ្លា រោមចិញ្ចើមក្រាស់. រោមភ្នែកវែង. សាច់ម៉ដ្ឋខៃ. សុដនមានជ្រលងល្អល្អះពេកកន្លង. រាងកាយរបស់នាងមានសភាពល្វត់ល្វៃឥតបើថ្លែងបាន...

ឱព្រះអើយ តើ ? តើបុប្ផសំខាន់របស់នាង មានរស់ជាតិប៉ុណ្ណាទៅ ? បបូរមាត់របស់នាងមានសភាពស្រស់សើមជានិច្ច បីដូចជាស្រទាប់ផ្កា ... ក្បៀករបស់នាងមានសភាពគួរឱ្យចង់ក្លែម, ដែលពោរពេញទៅដោយព្រៃស្រោង ...

— បានហើយបងផ្អែក, ដោយសារមីចាបញីដែលនៅក្រពុំដូចក្រពើញីឡើងខ្លួននេះ យើងនឹងបានរង្វាន់ជាច្រើន ហើយយើងរស់អស់កាលដ៏យូរ ប្រហែលជាយើងលែងប្រព្រឹត្តអំពើទុច្ចរិតទៀតហើយក៏មិនដឹង !

ស្ត្រីនិងបុរសនេះក៏គ្រាហ៍ខ្ញុំចូលទៅក្នុងបន្ទប់មួយ រួចក៏ចេញតាមទ្វារក្រោយហើយក៏ឡើងជណ្តើរ ។ ទោះបីទ្រូឌទ្រោមខាងផ្លូវកាយក៏ដោយ, ទោះបីជើងខ្ញុំគ្មានកម្លាំងនឹងបោះជំហានទៅមុខក្តី, ក៏ប៉ុន្តែខ្ញុំនៅចងចាំជានិច្ច "ខ្ញុំត្រូវតែគិត, ខ្ញុំត្រូវតែគិត, ខ្ញុំមិនត្រូវដេកទេ, ខ្ញុំមិនត្រូវដេកទេ, បើមិនដូច្នោះទេ ខ្ញុំនឹងវិនាសហើយ, ហើយគ្មាននរណាមករកខ្ញុំឃើញនៅទីនេះទេ !"

ខ្ញុំដឹងថា គេគ្រាហ៍ខ្ញុំឱ្យឡើងលើជណ្តើរ ដែលមាន១៥កាំ ដោយខ្ញុំរាប់ស្នូរណ្តំនៃជំហានជើង ។ តើខ្ញុំនៅទីណាឱព្រះពុទ្ធជាម្ចាស់អើយ!



ខ្ញុំឮស្នូរគេបើកទ្វារមួយ ។ គឺជាបន្ទប់ ។ ហើយក្នុងពេលជាមួយគ្នានោះខ្ញុំនឹកក្នុងចិត្តថា " ឱហ្ន៎, ប្រសិនបើខ្ញុំអាចក្អួតបាន, ពេលនេះប្រហែលជាខ្ញុំនឹងមានផ្លូវដោះខ្លួនបាន ។ គេអូសខ្ញុំទៅមុខជាថ្មីរួចគេលើកឡើងដាក់ទៅលើអ្វីមួយដែលខ្ញុំដឹងថា មានភាពទន់ត្រជាក់, គឺជាពូក ។ មួយរំពេចនោះខ្ញុំឮស្នូរក្រឹក ! ... គឺការបើកគន្លឹះភ្លើងអគ្គិសនី, ដែលមានពន្លឺជះមកលើត្របកភ្នែកខ្ញុំ ។ ខ្ញុំខំទប់អារម្មរបស់ខ្ញុំមិនឱ្យគេស្គាល់ទឹកមុខ ដែលឥតសន្លប់របស់ខ្ញុំឡើយ, ហើយខ្ញុំខំទប់រាងកាយរបស់ខ្ញុំកុំឱ្យកម្រើក ។ តាមពិតខ្ញុំធ្លាប់ត្រូវគេដាក់ថ្នាំសណ្តំម្តង, ក្នុងពេលដែលខ្ញុំត្រូវទទួលការវះកាត់ខ្នែងពោះវៀននៅមន្ទីរពេទ្យ ។

ខ្ញុំបានឮការសន្ទនានៃអ្នកពង្រត់ខ្ញុំមក ÷

— ម៉ោងប៉ុន្មានហើយបងផ្អែក ? បងឯងឥតបានរៀបចំឡានពេទ្យទេ, មែនទេ ?

— ម៉ោង១១ហើយ "អាស្រី" ... អ្នកណាទៅដឹងមុននឹងបានរៀបចំឡានពេទ្យ ? នេះគឺជាសំណាងមួយដែលយើងឥតបានព្រាងទុកទេតើ, ហើយការទៅមើលកុនរបស់យើងវាហុចផលប្រយោជន៍

មកដល់យើង. មិនថាអ៊ីចឹង ?

– បើអ៊ីចឹងបងផ្ញើកឯងត្រូវចាត់ការឱ្យបានស្រួល បន្តិចហើយយើងត្រូវសម្រួលជើងការណ៍ ពីព្រោះត្រួសាររបស់ស្រីនេះ . អាចនឹងទៅប្តឹងក្រសួងមានសមត្ថកិច្ច, ហើយប្រយ័ត្នតែមានភ្នាក់ងារណាម្នាក់ដែលគេកត់លេខរថយន្តយើងបាន ... ប៉ែ ! មិនមែនជារឿងស្រួលទេណា ! យើងត្រូវវៃលយ៉ាងម៉េច ចេញឱ្យផុតពីទីនេះនៅម៉ោង ១២ កន្លះ ។ ទៅយើងបិទភ្លើងទៅ ...

ស្នូរបិទកុងតាក់ភ្លើងនៅក្បែរខ្ញុំ. ហើយសម្លេងឆ្លើយឆ្លងគ្នាក៏ឮសូរល្វើយទៅៗ ក្រោយពីគេបិទទ្វារបន្ទប់ដែលខ្ញុំនៅហើយ ។

# ៤

# វិមាននរក

ខ្ញុំបើកភ្នែកភ្លាមក្នុងភាពងងឹតនៃរាត្រីចាក់ភ្នែកពុំយល់នេះ ។ ខ្ញុំផ្សៀង សោតាស្តាប់ដោយសេចក្តីភ័យញ័ររន្ធត់នៅក្នុងសេចក្តីសង្ឃឹមមួយដ៏ឆ្ងតលីលា ។ បន្តិចក្រោយខ្ញុំឮសូរទ្វារដែលនៅឯខាងក្រៅឯណោះរណ្តំ. ដែលធ្វើឱ្យខ្ញុំធូរទ្រូងសម្បើម រួចបន្ទាប់មកស្នូរពេទ៍នៃរថយន្ត ដែលបើកចេញទៅ ។

ខ្ញុំត្រឡប់ក្បាលលើខ្នើយ ហើយចលនាដ៏សែនខ្សោយនេះផ្តល់សេចក្តីសង្ឃឹមចំពោះខ្ញុំ ខទីមួយដោយសារវិមាននេះស្ងាត់ ហើយខទី២ដោយសារទីនេះគ្មានមនុស្សនៅទៀតផង ។ ការងងុយកំពុងតែលុកទន្រ្ទានខ្ញុំខ្លាំងពោសខ្ញុំ យកជ័យជំនះលើឆន្ទៈនេះទាល់តែបាន ។

ដំបូងបង្អស់ខ្ញុំត្រូវរិះរកមធ្យោបាយដើម្បីបើកភ្លើង ។ ពេលវេលាដែលនៅសល់សំរាប់ខ្ញុំខ្លីសែនខ្លី ។ ទីបំផុតខ្ញុំរាវទៅក៏ប៉ះនឹងចង្កៀងដែលគេដាក់លើតុសំរាប់បំភ្លឺនៅពេលដេក ។ ខ្ញុំខំប្រឹងយកដៃទាញគន្លឹះវាយ៉ាងអស់ទំហឹង ។ តាមពិតដៃខ្ញុំស្ទើរតែគ្មានកម្លាំងអ្វីបន្តិចសោះ ។ ក៏ប៉ុន្តែសេចក្តីតក់ស្លុតអាចធ្វើឱ្យខ្ញុំខំប្រឹងក្រោកអង្គុយបាន ។ ខ្ញុំសាកល្បងបោះជំហានម្តងមួយៗ ដោយយកដៃទប់គ្រែផង ។ បន្ទប់ទឹកនៅពីមុខនេះ ។ គឺជាសេចក្តីសង្ឃឹមរបស់ខ្ញុំមួយ ដូចដែលអ្នកស្រេកទឹកដើរកណ្តាល សមុទ្រខ្សាច់សាហារាបានជួបអណ្តូងទឹកមួយដូច្នោះ ។ ខ្ញុំមិនមែនត្រូវការផឹកទឹកទេ. ផ្ទុយទៅវិញខ្ញុំត្រូវការក្អួត. គឺក្អួតដើម្បីបញ្ចេញភាពពិសពុលនេះឱ្យអស់ ។ ជើងដ៏ទ្រុឌទ្រោមដោយអានុភាពថ្នាំរបស់ខ្ញុំពុំអាចទប់រាងកាយខ្ញុំបានឡើយ. ហើយទីបំផុតខ្ញុំក៏លុតជង្គង់ចុះយ៉ាងយឺតៗ ដោយជង្គង់ដ៏មាំនេះ ខ្ញុំកកិលបន្តិចម្តងៗ សំដៅទៅឯទ្វារបន្ទប់ទឹក ហើយលើកដៃកាន់ត្រមោងទ្វារធ្វើពីស្ពាន់បាន ។ ការខំប្រឹងជាចុងក្រោយបំផុត. ខ្ញុំក៏បើកទ្វារបន្ទប់ទឹកនេះបាន ។

គឺជាបន្ទប់ទឹកមួយដែលមានប្រដាប់ប្រើប្រាស់គ្រប់គ្រាន់តាម



សេចក្តីប៉ងប្រាថ្នារបស់ខ្ញុំ ។ បង្គន់មួយនៅទីនោះ ខ្ញុំយកដៃលូកទៅក្នុងបំពង់ករបស់ខ្ញុំ ហើយខ្ញុំខំប្រឹងក្អួត. ទីបំផុតខ្ញុំក៏បានសម្រេចរឿងនេះ ។ ខ្ញុំក្អួត. ក្អួតរហូតទាល់តែអស់ពីពោះ. ហើយក្លិនថ្នាំសណ្តំនេះធ្វើឱ្យខ្ញុំស្ទើរវិលមុខជាថ្មីម្តងទៀត ។ ក៏ប៉ុន្តែមិនជាអ្វីទេពិសពុលទាំងឡាយដែលសម្ងំក្នុងក្រពះខ្ញុំដើម្បីផ្សាយអានុភាព. ឥឡូវនេះវាចេញមកក្រៅអស់ទៅហើយ ...

ខ្ញុំកកិលខ្លួនជាថ្មីម្តងទៀតដើម្បីទៅកាន់គ្រែ. បំពង់កខ្ញុំស្ទើររហែកដោយសារការខំប្រឹងខាកនិងប្រឹងក្អួត. មុខរបស់ខ្ញុំទទឹកដោយសារទឹកដែលខ្ញុំលុបមុខឥតឈប់ឈរសោះ. អស់ជាច្រើននាទី ។ ក៏ប៉ុន្តែខ្ញុំមានការប្រុងប្រយ័ត្នណាស់ ពុំឱ្យសម្លៀកបំពាក់របស់ខ្ញុំទទឹកបន្តិចឡើយ ។

មិនគ្រាន់តែប៉ុណ្ណោះទេ ។ មុននឹងចេញពីបន្ទប់ទឹកមកខ្ញុំបានរៀបចំយ៉ាងស្អាតមិនទុកអ្វីជាស្នាកស្នាមឡើយ មុននឹងខ្ញុំវិលមកកាន់គ្រែនេះវិញ ។ អាឧត្បាតទាំងនេះអាចនឹងដឹងរឿងនេះនៅពេលដែលវាត្រឡប់មកវិញ ។

ឥឡូវនេះខ្ញុំត្រូវលៃលកយ៉ាងណា ដើម្បីចេញឱ្យផុតពីផ្ទះដ៏ចង្រៃ

ឧត្បាតនេះ ។ ហើយដល់ពេលនោះ ខ្ញុំអាចនឹងស្រែកបង្អកហៅឱ្យ
ជួយខ្ញុំគ្រប់ទិសទីបាន ។ ប៉ុន្តែអនិច្ចា ! ពុំដឹងជាហេតុអ្វីស្រាប់តែ
ផ្ងាកទៅក្រោយហើយក្បាលខ្ញុំកើយលើខ្នើយ ។ នៅក្នុងអាការៈ
ហត់ហេវកម្លាំងនេះ. មនសិការខ្ញុំឆ្លើយដោយស្រួលថា "ខ្ញុំដេក
សម្រាកតែ១០នាទីទេ. ខ្ញុំនៅសល់ពេលយ៉ាងតិច ណាស់ក៏មួយ
ម៉ោងដែរ ។ ពួកឧត្បាតអស់នោះវាថា វានឹងវិលត្រឡប់មកវិញ
នៅម៉ោង ១២ កន្លះរំលងអាធ្រាត ។ ខ្ញុំត្រូវតែគេងយកកម្លាំង
ខ្ញុំមិនឱ្យខកខ្លួនក្នុងការដេកនេះឡើយ. ដោយហេតុថាខ្ញុំបានក្អួតចោល
អស់នូវថ្នាំសណ្តំនេះហើយ..."

ទោះបីខ្ញុំជាមនុស្សដែលមានមហិទ្ធិឫទ្ធិខាងផ្លូវចិត្ត យ៉ាងដូចម្តេច
ក្តី.. ក៏ពលំកាយរបស់ខ្ញុំទ្រុឌទ្រោមអស់ហើយ ឯការងងុយក៏លុក
ទន្រ្ទានក្នុងពិភពនេត្រារបស់ខ្ញុំ ។ ដោយចលនាដ៏ទន់ល្វតល្វើយ.
ខ្ញុំពន្លត់ចង្កៀង ... ពេលវេលាកន្លងទៅយ៉ាងយឺតៗ. ដោយសេចក្តី
អាណិតអាសូរ ។ ក៏ប៉ុន្តែមនសិការមិនបានលះបង់ខ្ញុំចោលឡើយ ...

ស្រាប់តែមួយរំពេចនោះ ខ្ញុំភ្ញាក់ខ្លាក ហើយខ្ញុំត្រូវចំណាយពេល
អស់ច្រើន នាទីដើម្បីរំឭកព្រឹត្តិហេតុដែលកន្លងទៅ ។ នៅពេលដែល



ខ្ញុំបានវិលត្រឡប់មកជួបនឹងប្រាកដនិយមវិញ. គឺជាប្រាកដនិយមដ៏
គួរឱ្យតក់ស្លុតមួយ. ថាខ្ញុំកំពុងតែស្ថិតនៅក្នុងក្រញាំបិសាច. ខ្ញុំហៀប
នឹងស្រែកទៅហើយ .ស្រាប់តែបបូរមាត់ខ្ញុំខ្ទប់សម្លេងនេះមិនឱ្យខ្ទាត
ចេញមកក្រៅឡើយ ។ ខ្ញុំបន្ទោសអាត្មាឯងថា "ហេតុអ្វីបានជាខ្ញុំឆ្កួត
ទៅបណ្តោយអាត្មាឱ្យស្ថិតក្រោមអានុភាពនៃការងងុយដូច្នេះ. ត្រង់
ដែលថាខ្ញុំត្រូវចំណាយពេលវេលានេះ ដើម្បីរិះរកមធ្យោបាយរត់
ភៀសខ្លួននោះយ៉ាងណាទៅវិញ!"

ប្រហែលជាពួកវាវិលត្រលប់មកវិញទេដឹង នៅពេលដែលខ្ញុំ
កំពុងតែដេកនោះ ? ឱព្រះពុទ្ធជាម្ចាស់អើយ ! ឱព្រះពុទ្ធជាម្ចាស់
អើយ! ឱព្រះពុទ្ធជាម្ចាស់អើយ!

ខ្ញុំផ្ទៀងសោតាស្តាប់. បន្ទាប់មកដោយចលនាដ៏ស្ទាក់ស្ទើរ
របស់ខ្ញុំ. ខ្ញុំចុចគន្លឹះចង្កៀងបំភ្លឺវិញ ។ ដោយសេចក្តីរំភើបញាប់ញ័រ
ខ្ញុំមើលនាឡិកា ។ ម៉ោង១២និង១៧នាទីទៅហើយ ! គិតទៅខ្ញុំ
បានដេកជិត១ម៉ោង. គឺការសំរាកនេះហើយ ដែលញ៉ាំងឱ្យខ្ញុំមាន
កម្លាំងឡើងវិញ ។

ខ្ញុំក្រោកឡើងអង្គុយបានដូចបំណង ... ខ្ញុំដាក់ជើងចុះទៅលើ

កម្រាលឥដ្ឋ. ខ្ញុំធ្វើបានដូចបំណង ។ ខ្ញុំក្រោកឈរជើងទាំងពីរទ្ររាងកាយរបស់ខ្ញុំរួច ។ ខ្ញុំបោះជំហាន១ ២ ! ១ ២ ! ជំហានរបស់ខ្ញុំដើរទៅមុខបានយ៉ាងស្រួល ។ ខ្ញុំក៏ស្ទុះសំដៅទៅបង្អួច យកដៃញែករាំងននដែលបាំងពីក្នុង. ដើម្បីចោលនេត្រាមើលទៅខាងក្រៅ ។ អនិច្ចា ! គ្មានបង្អួចឯណាទេ គឺជាជញ្ជាំងស្មោះ. គេបានដាក់តែមឈើ. គឺបានដាក់រាំងនន គឺដើម្បីបំភ័ន្តភ្នែកអ្នករងគ្រោះតែប៉ុណ្ណោះ ដូច្នេះទីនេះគេបានគ្រោងទុកយ៉ាងប៉ិនប្រសប់បំផុត ។ តើនៅទីនេះមានមនុស្សរងគ្រោះប៉ុន្មាននាក់ហើយ ? តើខ្ញុំនៅក្នុងបន្ទប់នេះធ្វើអ្វី ? កុំថាឡើយតែខ្លាញ់. សូម្បីតែកន្លាតជាសត្វដ៏ល្អិតក្នុងគ្រាដែលវាទាល់ច្រកដូច្នេះវាត្រូវតែមុជរិះរក ត្បុលខាងណេះ ត្បុលខាងណោះ ដើម្បីសង្គ្រោះខ្លួនវាដែរខ្ញុំដើរសំដៅទ្វារហើយ សេចក្ដីសង្ឃឹមរបស់ខ្ញុំក៏រស់រវើកឡើងវិញ ។ កូនសោនៅទីនេះ ។ ឧក្រិដ្ឋជន ឥតបានចាក់សោទ្វារនេះឡើយ. ពីព្រោះអ្វី ? គ្មានអ្វីគួរឱ្យសង្ស័យឡើយ ឧក្រិដ្ឋជនដែលមានការពិសោធន៍ជាច្រើនណាស់មកហើយនោះ សុទ្ធតែយល់ថាអ្នករងគ្រោះពុំអាចភ្ញាក់ពីភាពសណ្ដំរបស់ខ្លួនមុនម៉ោង២នេះឡើយ ។ ដោយការពិសោធន៍ជាច្រើនដងមកហើយនោះ. ឧក្រិដ្ឋជនពុំយកចិត្ត



ទុកដាក់ចំពោះទ្វារនិងកូនសោនេះប៉ុន្មានឡើយ ព្រោះថាគេនឹងវិលត្រឡប់មកវិញមុនពេលអ្នករងគ្រោះដឹងខ្លួន ។ គេធ្លាប់ដឹងនិងធ្លាប់ឃើញតែដូច្នេះ ...

ក៏ប៉ុន្តែការស្មានរបស់វាខុស ព្រោះខ្ញុំពុំបានបណ្ដែតបណ្ដោយអាត្មាខ្ញុំឱ្យលុះនៅក្រោមសេចក្ដីតក់ស្លុត រហូតទាល់តែភ្លេចខ្លួនភ្លេចប្រាណនោះទេ ហើយម្យ៉ាងទៀតកម្មួតរបស់ខ្ញុំអាចនឹងបន្ថយបន្សាបអានុភាពនៃថ្នាំសណ្ដំនេះ ដែលហេតុបណ្ដាលឱ្យខ្ញុំភ្ញាក់មុនពេលឧក្រិដ្ឋជនស្មាន ។

ដោយកម្លាំងដៃរបស់ខ្ញុំ. ខ្ញុំក៏បើកទ្វារនេះបានដោយហត់គឃូ ។

រាត្រីកាលខ្មៅងងឹតចាក់ភ្នែកពុំយល់ ពីលើក្បាលជណ្ដើរនេះធ្វើឱ្យខ្ញុំមានសេចក្ដីតក់ស្លុតតក្កមា ។ ក៏ប៉ុន្តែសភាពស្ងប់ស្ងាត់បានធ្វើឱ្យខ្ញុំមានការនឹងនក្នុងចិត្ត ។ ខ្ញុំមានសេចក្ដីសង្ឃឹមមួយ. ពីព្រោះថាមានឧក្រិដ្ឋជនតែ២ នាក់ប៉ុណ្ណោះនៅក្នុងផ្ទះនេះ. មិនថាអ៊ុំចឹង ?

តើកុងតាក់ភ្លើងនៅឯណា. នៅឯណា ? ពេលនេះខ្ញុំត្រូវការកុងតាក់ភ្លើងជាចាំបាច់បំផុត ដូចដែលរថយន្តត្រូវការចង្កូតឥតចៀសបានឡើយ ។ ខ្ញុំនឹកស្ទើបនៅឯបាតជើងរបស់ខ្ញុំខ្លាំងណាស់. ពីព្រោះខ្ញុំ

ព្រួយបារម្ភខ្លាចជើងនេះជាន់ទៅនឹងកន្លែងទទេ ហើយខ្លួនខ្ញុំនឹងធ្លាក់ទៅក្នុងអន្ទាក់ណាមួយដូចជាអន្លង់ដែល មានចម្រឹងដែក. ដូចជាកន្លែងទ្រុងរបស់សត្វចចក ឬគុហាមួយដែលមាន លលាដ៍ក្បាលខ្មោច និងឆ្អឹងឆ្អែងរកេតរកូតមីដេរដាស ... អ្នកណាដឹងបាន ? ខ្ញុំស្រមៃសព្វគ្រប់បែបយ៉ាង ដូចដែលខ្ញុំបានអានប្រលោមលោកដ៏គួរឱ្យព្រឺគ្រប់រោម. ដែលគេនិយាយអំពីវិមានរបស់បិសាច ...

ដៃរបស់ខ្ញុំរាវស្ទាបជញ្ជាំងជានិច្ច ហើយស្រាប់តែប៉ះនឹងរបស់អ្វីមួយដែល ខ្ញុំយល់ថាជាកុងតាក់ភ្លើងខ្ញុំក៏ចុចគន្លឹះវា ។ ពន្លឺបានជះតាមជណ្តើរដែលមានជញ្ជាំងពីរអមជិតបីដូចជាទ្រុងដូច្នោះ ។ គឺជាជណ្តើរដ៏ចាសរិចរិល ...

ពេលវេលាខ្លីណាស់នៅសល់តែជាង ១០នាទីប៉ុណ្ណោះ ខ្ញុំក៏ឈានជើងចុះតាមជណ្តើរ ដែលមានកាំទំហំតូចៗ ហើយជូនកាលខ្ញុំលោតដោយសារកាំជណ្តើរនេះប្រេះពុក ព្រោះស៊ីម៉ងត៍ចាស់យូរឆ្នាំ ។ បន្ទប់នៅខាងលើដែលខ្ញុំទើបនឹង ចាកចោលមកនេះគឺជាបន្ទប់តែមួយគត់ដែលមានសង្ហារិមភ័ណ្ឌនិងបន្ទប់ទឹក ។ ដូច្នេះវិមាននេះគឺជាវិមានដែលឧក្រិដ្ឋជនយកជនរងគ្រោះមកដាក់នៅទីនេះ មុននឹងនាំទៅកាន់



ទីដទៃទៀត ... ខ្ញុំចុះជណ្តើរមកដល់ជាន់ខាងក្រោម ជញ្ជាំងហ៊ុំព័ទ្ធជិតទៀត ។ ខ្ញុំពុំទាន់បានចេញផុតអំពីព្រំដែននៃវិមាននេះនៅឡើយទេ. ខ្ញុំសង្ឃឹមថា កាលបើខ្ញុំចុះផុតជណ្តើរ. ខ្ញុំនឹងបានឃើញផ្ទៃមេឃនិងដួងតារាទាំងឡាយ ។ ក៏ប៉ុន្តែអនិច្ចា ! សេចក្តីសង្ឃឹមរបស់ខ្ញុំរលត់រលាយភ្លាម ។ ខ្ញុំគ្មានឃើញផ្ទៃមេឃប៉ុនបាតដៃ ឬដួងតារាមួយគ្រាប់ឡើយ. តើខ្ញុំស្រែកឱ្យនរណាស្តាប់. ឱ្យនរណាឮ. មិនបានន័យថាខ្ញុំស្រែកដើម្បីវិមាននេះទេឬ ?

នេត្ររបស់ខ្ញុំក្រឡែកទៅឆ្ងាយក៏ប្រទះឃើញទ្វារដែកមួយដ៏មាំមួន ។. ខ្ញុំស្ទុះទៅ. សេរីភាពខ្ញុំនៅត្រង់ទ្វារនេះ. ជីវិតខ្ញុំនៅត្រង់ទ្វារនេះ បើទ្វារនេះរបើកហើយ ប្រហែលជាសេចក្តីតក់ស្លុតរបស់ខ្ញុំនឹងរលត់រលាយជាពុំខានឡើយ ...

ប៉ុន្តែអនិច្ចា ! នៅពេលដែលខ្ញុំមកដល់ទ្វារនេះ ទើបខ្ញុំដឹងថាខ្ញុំធ្លាក់នរកម្តងទៀតហើយ ។ ទ្វារនេះឥតមានគន្លឹះអ្វីទាំងអស់ ។ ចុះហេតុអ្វីក៏វារឹងម៉ឹងម្ល៉េះ ? ក្នុងខណៈនោះ. ខ្ញុំយល់ហើយថាគន្លឹះគេដាក់នៅខាងក្រៅឯណោះ គឺថាទ្វារដែលគេធ្វើឡើងតាមរបៀបទ្វារគុក ។ វិមាននេះគេសង់ឡើងសំរាប់តែធ្វើឧក្រិដ្ឋកម្មប៉ុណ្ណោះ. គឺថា

គេបានរៀបជើងព្រួលសម្រួលជើងការណ៍យ៉ាងស្រេចបាច់អស់ ...

ហួសពីខ្លាច. ខ្ញុំលែងខ្លាចព្រោះខ្ញុំយល់ច្បាស់ថា សេចក្តីសង្ឃឹមរបស់ខ្ញុំរលត់រស្មីហើយ ។ ខ្ញុំដើររុកកកាយឱ្យតែឃើញមានច្រក. គឺច្រកចេញ ។ ក៏ប៉ុន្តែច្រមុះរបស់ខ្ញុំប៉ះតែនឹងជញ្ជាំងគ្រប់ទិសទី ។

ក្នុងពេលនោះ ខ្ញុំហាក់ដូចជាធុំក្លិនអ្វីដែលហៅថាក្លិនដុះផ្សិត ។ ខ្ញុំក៏ដើរចូលក្នុងបន្ទប់មួយនោះ ។ គឺជាបន្ទប់ផ្ទះបាយ ។ វត្ថុទីមួយដែលខ្ញុំបានឃើញគឺបង្អួចនៅឯជញ្ជាំង ។ ខ្ញុំស្ទុះទៅជាថ្មីដោយសង្ឃឹមថា បង្អួចនេះនឹងបែរទិសទៅខាងក្រៅវិមានឬចំហៀងវិមាន ដែលខ្ញុំយល់ថាពិតជាមានភូមិគ្រឹះរបស់អ្នកដទៃ ស្ថិតនៅទីជិត១ ហើយខ្ញុំនឹងខំប្រឹងស្រែកឡើងទាញយកសេចក្តីប្រុងប្រយ័ត្ន និងជំនួយពីពួកនៅជិតនេះ ។ ខ្ញុំនៅសល់៧ ឬ ៨នាទីទៀតដែរ ដើម្បីផ្សងសំណាង ។ អនិច្ចានៅពេលដែលខ្ញុំមកដល់. ពុំមែនជាបង្អួចពិតនោះទេ គឺជាបង្អួចក្រឡៃដូចនៅក្នុងបន្ទប់នៅខាងលើដូច្នោះ ។ តើគេសង់បង្អួចក្រឡៃនេះធ្វើអ្វី ? អស់សង្ឃឹមខ្ញុំស្រយុតស្រយង់អស់ដួងព្រលឹង ...

ក៏ប៉ុន្តែខ្ញុំមិនចាញ់ទេ ។ ខ្ញុំលើកដៃតប់ជញ្ជាំងត្រង់បង្អួចនេះ ៣ ៤ ដៃ ដោយសង្ឃឹមថាក្រែងជាទ្វារសម្ងាត់អ្វីអាចចេញទៅបាន ។



ជាការធម្មតាទេ ក្នុងវិមានឧក្រិដ្ឋកម្មមានកន្លែងបិទជិត ក៏មែនពិត ហើយប៉ុន្តែត្រូវតែមានច្រកសម្ងាត់សំរាប់ចេញទៅដែរ ក្នុងពេលឧក្រិដ្ឋជននោះត្រូវប៉ូលីសរកមុខឃើញ. ហើយដែលជាពន្លឺចុងក្រោយបំផុតសំរាប់ឧក្រិដ្ឋជនក្នុងការភៀសខ្លួនចេញ អនិច្ចា. ជញ្ជាំងគឺជញ្ជាំងដដែល. ខ្ញុំបែរក្បាលផាំងរេមើលក្នុងបន្ទប់ ។ ក្បាលម៉ាស៊ីនទឹកមួយក្រខ្វក់ ហើយទឹកនៅស្រក់តក់១ នៅឡើយ ។ គ្រប់ទីកន្លែងមានភាពក្រខ្វក់និងក្លិនដុះផ្សិតដែលជាសញ្ញាឱ្យយល់ថា ផ្ទះបាយនេះគេឥតប្រើប្រាស់ឡើយ ។ នៅឯជ្រុងម្ខាងតុកំបាក់ជើងមួយនៅទីនោះ ហើយនៅពីលើ ខ្ញុំឃើញនំប៉័ងប្រវែងមួយចំអាមនិងត្រីខកំប៉ុង ដែលបើកហើយស្រេចសល់ជាងពាក់កណ្តាល ។ ដូច្នេះឧក្រិដ្ឋជនម្នាក់ឬពីរនាក់នេះ ពិតជាបានចូលមកក្នុងបន្ទប់នេះ ក្រោយពីបានគ្រាហ៍ខ្ញុំយកទៅចោលនៅឯក្នុងបន្ទប់ខាងលើឯណោះ ។ ហើយដោយឃ្លានពេកគេក៏ប្រញាប់ប្រញាល់បរិភោគដើម្បីចេញទៅខាងក្រៅ ... ដូច្នេះខ្ញុំមិនត្រូវទុកដាន ឬស្លាកស្នាមអ្វីក្នុងទីនេះឡើយ ។ ក៏ប៉ុន្តែមុននឹងខ្ញុំចេញ ភ្នែករបស់ខ្ញុំខំរេរកគ្រប់កន្លែងក្រែងឃើញមានកាំបិត ឬអាវុធអ្វីមួយសំរាប់ជាមធ្យោបាយជួយដោះគ្រោះរបស់ខ្ញុំ ។

គ្មានអ្វីសោះ. គ្មានអ្វីទាល់តែសោះ ។ ព្រោះវិមាននេះ វិមានដ៏ចាស់នេះ វិមានបិសាចនេះ ពុំមែនសម្រាប់អាស្រ័យនៅទេគឺសំរាប់ធ្វើជាមន្ទីរឃុំឃាំងអ្នករងគ្រោះ ...

ខ្ញុំបើកថតតុ ខ្ញុំរើកកាយកន្លែងខ្លះៗ ដោយប្រុងប្រយ័ត្ន ប៉ុន្តែខ្ញុំគ្មានប្រទះនឹងអ្វីសោះ ។ ស្រាប់តែមួយរំពេចនោះនៅលើតុមានវត្ថុមួយដែលបានទាញសេចក្ដីប្រុងប្រយ័ត្នរបស់ខ្ញុំ គឺជាសេចក្ដីសង្ឃឹមដ៏តូចមួយ ។ តើវត្ថុនោះពុំមែនជាអាវុធទេឬ ? គឺជាអាវុធទន់ខ្សោយពិបាកប្រើប្រាស់ ក៏ប៉ុន្តែវាជាអាវុធមួយដែរ ... ក្នុងគ្រាខ្យល់ព្យុះខ្លាំង. ម្ចាស់សំពៅមិនចាំបាច់រើសកំពង់ផែទេ ... ផែណាក៏ដោយឱ្យតែផែ គេត្រូវតែចូលចតសិន ! ក្នុងពេលតណ្ហាកម្រើកខ្លាំង. បុរសស្ត្រីមិនចាំបាច់រើសគូប្រយុទ្ធស្អាតល្អនោះទេ. ល្មមៗ ក៏បានដែរ ឱ្យតែគូប្រយុទ្ធមានប្រដាប់សំរាប់ប្រើប្រាស់ បំរើកាមកិលេសរបស់ខ្ញុំ. មិនថាអ៊ីចឹង ?

ខ្ញុំក៏ចាប់អាវុធនេះក្ដាប់ក្នុងដៃ ។ រួចខ្ញុំថយក្រោយហើយខ្ញុំដើរយ៉ាងប្រុងប្រយ័ត្ន ដោយពន្លត់ចង្កៀងនៅពេលដែលខ្ញុំឡើងផុតជណ្ដើរ ។ ខ្ញុំឡើងជណ្ដើរដើម្បីវិលមកក្នុងបន្ទប់របស់ខ្ញុំវិញ. ក្រោយ



ពីការដើរអស់រយៈកាលជាង១០នាទីទាំងឥតប្រយោជន៍ ។ មែនកាលដំបូងខ្ញុំចុះទៅខាងក្រោម ជាសេចក្ដីប្រាថ្នារបស់ខ្ញុំតែមួយដើម្បីរត់គេចខ្លួន ព្រោះតែហេតុនេះហើយបានជាខ្ញុំភ្លេចមើលអ្វីៗ ទាំងអស់នៅឯជាន់ខាងលើជិតបន្ទប់របស់ខ្ញុំ។ នៅក្បែរបន្ទប់ខ្ញុំ. ខ្ញុំឃើញបន្ទប់តូចមួយទៀត ... បន្ទប់ស្អី ? ខ្ញុំនឹកព្រឺខ្លួន. ក្រែងជាបន្ទប់ដែលគេដាក់ខ្មោចទេដឹង ? គឺជាបន្ទប់បិសាច ឬបន្ទប់ធ្វើឃាដមនុស្សទេដឹង ?

មិនជាការចម្លែកទេ ក្នុងវិមានមួយដែលឧក្រិដ្ឋជនសាងសំរាប់ប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួននោះ គេតែងតែសាងកន្លែងមួយសំរាប់លាងឧក្រិដ្ឋកម្មនេះដែរ ។ ឧបមាថាបើឧក្រិដ្ឋជននេះភ្លាត់ស្នៀត ឧបមាថា បើអ្នករងគ្រោះនេះមានសំណាងដោយប្រការណាមួយក្នុងការស្គាល់មុខឧក្រិដ្ឋជននេះ ការតែម្យ៉ាងដែលគេធ្វើចំពោះអ្នករងគ្រោះគឺសេចក្ដីស្លាប់ ...

ខ្ញុំយកដៃប្រានទ្វារបន្ទប់នេះសាកមើល ។ ទ្វារក៏របើកថ្នមៗ ដោយបញ្ចេញសូរស័ព្ទលាន់ទ្រហឹង ដែលបណ្ដាលឱ្យខ្ញុំព្រឺខ្លាកៗ ក្នុងខ្លួន. ក្រែងភ្នែករបស់ខ្ញុំប៉ះលើទស្សនីយភាពដ៏ឃោរឃៅណាមួយ ។

បន្ទប់ងងឹតឈឹង ។ កែវភ្នែករបស់ខ្ញុំដែលមានទម្លាប់ក្នុងអន្ធការទៅហើយនោះ ខ្ញុំប្រទះឃើញកុងតាក់ភ្លើងមួយ ។ ខ្ញុំក៏ចុចគន្លឹះនេះភ្លាម. រស្មីអគ្គិសនីក្រហមប្រេញជះពេញក្នុងបន្ទប់ ដែលគ្មានភាពស្អាតស្អំបន្តិចសោះ ។ ក្នុងមួយខណៈនោះឯងនេត្រាខ្ញុំស្រវាំងហើយបេះដូងខ្ញុំកាំងអស់ ។ តើខ្ញុំឃើញអ្វី ? តើខ្ញុំឃើញអ្វ ?

ឱព្រះអើយ ! ឱព្រះអើយ ! ទូរស័ព្ទមួយនៅទីនេះគឺទូរស័ព្ទមួយ ! សេចក្តីសង្ឃឹមមួយ ! គឺជីវិតថ្មី !

ខ្ញុំហាក់សំដៅទូរស័ព្ទនេះដូចជាសិង្ហលោតសំដៅឈ្លូស ដែលជាភក្សាហាររបស់ខ្លួនដូច្នោះ ។ ខ្ញុំលើកដៃទូរស័ព្ទ ... ហើយក៏វាវលេខផ្ទះរបស់ខ្ញុំ ។ សូររោទ៍ទូរស័ព្ទនៅឆ្ងាយឯណោះ បន្លឺឡើងយ៉ាងវែងយ៉ាងយូរ. មួយនាទីសំរាប់ខ្ញុំ ហាក់បីដូចជាមួយម៉ោង. យូរអ្វីម្លេះ ? គ្មាននរណាឆ្លើយតបសោះ ។ ខ្ញុំយកដៃសង្កត់គន្លឹះទូរស័ព្ទដើម្បីផ្តាច់ការទាក់ទងលើកទី១ ហើយខ្ញុំក៏វាវលេខថ្មីដើម្បីហៅបងវិចិត្រ ។ សូររោទ៍ឯឆ្ងាយឯណោះក៏បន្លឺជាថ្មីទៀត ។ រោទ៍យូរ អើយសែនយូរ. ក៏ប៉ុន្តែគ្មាននរណាឆ្លើយសោះ ។ តើបងវិចិត្រកំពុងតែតាមរកខ្ញុំទេដឹង ?



ខ្ញុំនឹកឃើញប៉ូលិស ។ តើទូរស័ព្ទរបស់ប៉ូលិសលេខប៉ុន្មានទៅ ? មិនដឹងទាល់តែសោះ ។

ស្រាប់តែមួយរំពេចនោះ ខ្ញុំគាំងខ្លួនបីដូចជាចរន្តឈាមលែងរត់ដូច្នោះ ។ សូររថយន្តមួយបន្លឺនៅឯផ្លូវខាងមុខឯណោះ ។

ឃើតណាសហើយសំរាប់ខ្ញុំ ! ខ្ញុំគ្មានពេលដើម្បីរំដោះខ្លួនខ្ញុំទៀតទេ ! ពួកឧក្រិដ្ឋជននឹងមកដល់ហើយ កាលបើវាដឹងថាខ្ញុំនៅទីនេះ. វានឹងសម្លាប់ខ្ញុំ ព្រោះវាមានកាំភ្លើងមួយ. នេះជាការឥតសង្ស័យឡើយ ... ខ្ញុំក៏លូកដៃចុចពន្លត់ ចង្កៀងក្រោយពីដាក់ដៃទូរស័ព្ទគងត្រឹមត្រូវហើយ ។ ខ្ញុំបិទទ្វាររួចក៏ចូលក្នុងបន្ទប់របស់ខ្ញុំវិញ. ក្នុងពេលនោះ ខ្ញុំឮសូរទ្វារដែកឯក្រៅបើកត្រាំងៗ ឡើង ។ ឡានដែលចូលមកម្តងនេះ. តាមសំដីដែលឧក្រិដ្ឋជននិយាយថាជាឡានពេទ្យ ដែលកំពុងតែចូលចតនៅឯទីធ្លា ។ ខ្ញុំច្រានទ្វារបន្ទប់របស់ខ្ញុំបិទមកវិញ ដូចគ្រាដើមដូច្នោះ ។

ខ្ញុំចិញ្ចឹមសេចក្តីសង្ឃឹមថ្មីមួយទៀត ពីព្រោះឧក្រិដ្ឋជននឹងជឿថាខ្ញុំនៅតែពុលថ្នាំនៅឡើយ ។ បើទេវតាប្រោសប្រណីឱ្យខ្ញុំនៅរនេះ ៤ - ៥ នាទីជាមួយនឹង "អាប្រុស" នោះប្រហែលជាខ្ញុំមាន

ភ័ព្វសំណាង ។ គឺថាក្រោយពី "អាប្រុស" នេះរងគ្រោះដោយសារអាវុធរបស់ខ្ញុំហើយ "មីស្រីប្រហែលជាគ្មានលទ្ធភាពនឹងចាប់គ្រញិចខ្ញុំដោយដៃទទេ ទេដឹង ។

ខ្ញុំឡើងលើគ្រែ ហើយគេងសណ្ដូកកាយធម្មតា ខំទប់អារម្មណ៍និងជីពចររបស់ខ្ញុំកុំឱ្យលោតខ្លាំងពេក ។ នៅឯខាងក្រោមខ្ញុំឮសូរទ្វាររអ៊ើត្អា ហើយរបើកឡើងបន្ត១ គ្នា រួចបន្ទាប់មកសូរឡើងជណ្ដើរមួយ១ ...

តាមខ្ញុំយល់ការចេញដំណើរតាមឡានពេទ្យ ពុំមែនធ្វើឡើងភ្លាមនោះទេ តើពួកឧក្រិដ្ឋជននេះត្រូវការអ្វីទៀត ។

ខ្ញុំនឹកឃើញរឿងមួយនោះ ខ្ញុំតក់ស្លុតឡើងព្រឺខ្លួន ។ "អាប្រុស" នោះពុំមែនជាតាចាស់នោះឡើយ ។ សំដីរបស់វា ដៃរបស់វាដែលកាន់ចង្កូតរថយន្តបញ្ជាក់ឱ្យដឹងជាភ័ស្តុតាងស្រាប់ ។ ដូច្នេះខ្ញុំត្រូវធ្វើការប្រយុទ្ធ ជាមួយនឹងបុរសមួយរូបដែលកំពុងពេញកម្លាំង ។ ក្នុងពេលជាមួយគ្នា ខ្ញុំរលឹកឃើញរឿងព្រេងនិទានដែលគេតែងនិយាយអំពីសត្វក្ងាន់ធ្វើពុតជាស្លាប់ ដើម្បីឆ្លៀតឱកាសរំដោះខ្លួនបានក្នុងពេលដែលអ្នកស្រែម្នាស់អន្ទាក់ពុំបានចាប់ភ្ជឹក ។ ខ្ញុំក្ដាប់អាវុធ ដ៏តូចនេះជាប់ ហើយខ្ញុំបន្ទំដាក់ដៃក្រោមកម្រាលពូក ដែលឧក្រិដ្ឋជនបានដណ្ដប់ឱ្យខ្ញុំ ។ ខ្ញុំឮសូរសម្លេងជជែកគ្នានៅខាងក្រៅ ហើយមួយរំពេចនោះ ខ្ញុំឮសូរក្បាលត្រមោងទ្វារកម្រើកក្រិចក្រុក១ រួចទ្វារក៏របើកឡើង ...



ខ្ញុំខំទប់ចេតនារម្មណ៍និងបសាទរបស់ខ្ញុំទាំងមួយពាន់ ដើម្បីកុំឱ្យខ្ញុំធ្វើចលនាអ្វីដែលបណ្ដាលឱ្យឧក្រិដ្ឋជនដឹងនិងទាយថា ខ្ញុំនេះពុំមែនសន្លប់ដូចដែលវាស្មាននោះទេ ។ ឱះ ឱ វានឹងបើកភ្លើងឥឡូវហើយ ! ហើយកាលបើភ្លើង អគ្គិសនីបំភ្លឺមកតើត្របកភ្នែករបស់ខ្ញុំកម្រើកទេ ? អូយ ! ខ្ញុំខំទប់រកអ្វីប្រៀបផ្ទឹមពុំបាន ...

ខ្ញុំឮសូរក្រឹក. គឺជាគន្លឹះអគ្គិសនីដែលវាទើបតែនឹងចុច ...